# ជូនចំពោះក្រុមហ៊ុនទទួលនិងអ្នកហាត់រៀន

ពេលដែលអ្នកហាត់រៀនទៅមន្ទីរពេទ្យ សូមយក«សំបុត្រពីការព្យាបាលនៃអ្នកហាត់រៀនAOTS»(នៅខាងក្រោមចែងថា«កាតវេជ្ជសាស្ត្រ») «វិក័យប័ត្រខាងវេជ្ជសាស្ត្រនៃអ្នកហាត់រៀនម្នាក់ៗ»និង«សេចក្តីស្នើសុំសម្រាប់ពេលអ្នកហាត់រៀនAOTSទៅមន្ទីរពេទ្យ»(ដាក់កាតវេជ្ជសាស្ត្រ)ទៅជាមួយផង ហើយសូមធ្វើតាមការណែនាំដូចខាងក្រោម។ (បើទទួលថ្នាំនៅខាងក្រោមមន្ទីរពេទ្យ សូមធ្វើដូចនេះនៅឱសថស្ថាន) ហើយពេលទៅមន្ទីរពេទ្យ សូមទៅជាមួយនឹងបុគ្គលិកម្នាក់របស់ក្រុមហ៊ុនទទួលផង។

## នៅកន្លែងទទួលភ្ញៀវនៃមន្ទីរពេទ្យ




សូមបង្ហាញ«សំបុត្រពីការព្យាបាលនៃអ្នកហាត់រៀនAOTS»(កាតវេជ្ជសាស្ត្រ) និង«សេចក្តីស្នើសុំសម្រាប់ពេលអ្នកហាត់រៀនAOTSទៅមន្ទីរពេទ្យ»ដល់អ្នកទទួលភ្ញៀវ។

(កំណត់សម្គាល់)កាតនេះអាចប្រើបានសម្រាប់ថ្លៃព្យាបាលពេលមានជម្ងឺឬរបួសគ្រោះថ្នាក់ណាមួយដែលបានកើតឡើងក្នុងរយៈពេលហាត់រៀន។
កាតនេះមានសុពលភាពក្នុងរយៈពេល១៨០ថ្ងៃគិតចាប់ពីថ្ងៃទៅមន្ទីរពេទ្យជាលើកទីមួយឬថ្ងៃដែលត្រូវរបួស។




សូមកត់ពត៌មានចាំបាច់ដូចជាឈ្មោះអ្នកហាត់រៀន ពាក្យសញ្ញាឈ្មោះអ្នកទទួលស្គាល់ស្ថានភាពជាដើមលើ«វិក័យប័ត្រខាងវេជ្ជសាស្ត្រនៃអ្នកហាត់រៀនម្នាក់ៗ»រួចឲ្យដល់អ្នកទទួលភ្ញៀវ។

← សូមកត់ពត៌មាននៅក្នុង«កាតវេជ្ជសាស្ត្រ»។

← សូមកត់ពត៌មានចាំបាច់ដូចជាពាក្យសញ្ញា ថ្ងៃខែដែលចាប់ផ្តើមឈឺជាដើម។
ជាអ្នកទទួលស្គាល់ស្ថានភាព សូមកត់ឈ្មោះរបស់អ្នកដែលទៅជាមួយគ្នាឬអ្នកទទួលខុសត្រូវខាងការបង្ហាត់ឬអ្នកដឹកនាំខាងជីវភាពជាដើម។

## របៀបបង់ថ្លៃវេជ្ជសាស្ត្រ

១)ករណីអ្នកហាត់រៀនមិនបង់ថ្លៃវេជ្ជសាស្ត្រដល់មន្ទីរពេទ្យ
ដោយសារសេចក្តីសប្បុរសរបស់មន្ទីរពេទ្យ មន្ទីរពេទ្យមិនតម្រូវឲ្យអ្នកជម្ងឺបង់ថ្លៃវេជ្ជសាស្ត្រនៅឯកន្លែងទទួលភ្ញៀវទេ តែមន្ទីរពេទ្យនឹងផ្ញើ«វិក័យប័ត្រខាងវេជ្ជសាស្ត្រនៃអ្នកហាត់រៀនម្នាក់ៗ»ដល់AOTSដើម្បីស្នើសុំបង់ថ្លៃវេជ្ជសាស្ត្រ នោះក្រុមហ៊ុនធានារ៉ាប់រងនឹងបង់ថ្លៃចំណាយនោះដល់មន្ទីរពេទ្យនៅថ្ងៃក្រោយ។ ដូច្នេះ ជាទូទៅមិនមានការបង់ថ្លៃនៅឯកន្លែងទទួលភ្ញៀវឡើយ។

២)ករណីអ្នកហាត់រៀនឬក្រុមហ៊ុនទទួលនឹងបង់ថ្លៃវេជ្ជសាស្ត្រដល់មន្ទីរពេទ្យ
មានករណីខ្លះដែលមន្ទីរពេទ្យតម្រូវឲ្យបង់ថ្លៃនៅឯកន្លែងទទួលភ្ញៀវដែរ។ ពេលនោះ សូមបង់ថ្លៃផង។
ក្នុងករណីនោះ បើក្រុមហ៊ុនទទួលនឹងផ្ញើ «វិក័យប័ត្រខាងវេជ្ជសាស្ត្រនៃអ្នកហាត់រៀនម្នាក់ៗ» ដល់AOTS នោះក្រុមហ៊ុនធានារ៉ាប់រងនឹងបង់ថ្លៃវេជ្ជសាស្ត្រដល់ក្រុមហ៊ុនទទួល។
<របៀបស្នើសុំថ្លៃវេជ្ជសាស្ត្រ>
①កត់ថ្ងៃខែដែលទៅមន្ទីរពេទ្យដំបូងនិងឈ្មោះជម្ងឺឬរបួសនៅក្បែរជួរអ្នកទទួលស្គាល់ស្ថានភាពក្នុងវិក័យប័ត្រនោះ(ករណីរបួស កត់ពីថ្ងៃខែដែលត្រូវរបួស)
②កត់ឈ្មោះក្រុមហ៊ុនទទួលនៅជួរអ្នកស្នើសុំថ្លៃវេជ្ជសាស្ត្រក្នុងវិក័យប័ត្រនោះ ហើយកត់លេខគណនីធនាគាររបស់ក្រុមហ៊ុនទទួលជាអ្នកទទួលលុយ។
③ផ្ញើវិក័យប័ត្រនោះនិងបង្កាន់ដៃបង់ប្រាក់(ដើម)ដល់AOTS។
④នៅចុងខែបន្ទាប់ ក្រុមហ៊ុនធានារ៉ាប់រងនឹងផ្ញើលុយចូលក្នុងគណនីធនាគារជាកំណត់។

## ករណីបង់ថ្លៃនៅឱសថស្ថាន

ពេលត្រូវបង់ថ្លៃថ្នាំនៅឱសថស្ថាន សូមបង្ហាញ«វិក័យប័ត្រខាងវេជ្ជសាស្ត្រនៃអ្នកហាត់រៀនម្នាក់ៗ» «កាតវេជ្ជសាស្ត្រ» និង«សំបុត្រពីការព្យាបាលនៃអ្នកហាត់រៀនAOTS» ដូចករណីដែលបានចែងនៅខាងលើ។ របៀបបង់ថ្លៃក៏ដូចគ្នាដែរ។ ប៉ុន្តែពេលដែលក្រុមហ៊ុនទទួលត្រូវបង់ថ្លៃថ្នាំដល់ឱសថស្ថាន សូមសរសេរពីថ្ងៃខែដែលទៅមន្ទីរពេទ្យជាលើកដំបូង ឈ្មោះជម្ងឺ និងឈ្មោះមន្ទីរពេទ្យនៅក្បែរជួរអ្នកទទួលស្គាល់ស្ថានភាពក្នុង «វិក័យប័ត្រខាងវេជ្ជសាស្ត្រនៃអ្នកហាត់ រៀនម្នាក់ៗ»។

## ទំនាក់ទំនង

The Association for Overseas Technical Cooperation and Sustainable Partnerships (AOTS)
Project Accounting Group, Corporate Liaison Department
30-1, Senju-Azuma 1-chome, Adachi-ku, Tokyo 120-8534, Japan　TEL: +81-3-3888-8220　FAX: +81-3-3888-8428
URL: www.aots.jp